# PNEUMOCOCCAL POLYSACCHARIDE

# ថ្នាំចាក់បង្ការជម្ងឺរលាកសួត ន្ញូមូកូកុល-ផលីសាកាវ៉ៃដ៍

## អ្វីដែលអ្នកចាំបាច់ត្រូវដឹង

មានពិតមានរៀបរាប់អំពីថ្នាំបង្ការរោគជាច្រើនជាភាសាអិស្ប៉ាញ៉ុលនិងភាសាដ៏ទៃទៀត ។សូមចុចទៅ www.immunize.org/vis.

## 1 ជម្ងឺ Pneumococcal

ជម្ងឺ Pneumococcal បណ្តាលមកពីមេរោគម្យ៉ាងឈ្មោះ *Streptococcus pneumoniae* ។ វាជាបុព្វហេតុចេញមុខ បណ្តាលឱ្យមានជម្ងឺដែលធ្វើឱ្យមានការចាក់ថ្នាំបង្ការ និងមានសេចក្តីស្លាប់ នៅក្នុងសហរដ្ឋ ។ អ្នកណាម្នាក់ក៏អាចមានជម្ងឺរលាកសួតបានដែរ ប៉ុន្តែមានអ្នកខ្លះអាចមានគ្រោះថ្នាក់ជាង អ្នកខ្លះទៀត:

- មនុស្សអាយុ៦៥ឆ្នាំឡើងទៅ
- មនុស្សក្មេងបំផុត
- មនុស្សមានបញ្ហាសុខភាពផ្សេងៗ
- មនុស្សដែលមានប្រព័ន្ធសំរាប់ឱ្យស៊ាំដល់រោគនានា-ចុះខ្សោយ
- មនុស្សជក់បារី

ជម្ងឺ Pneumococcal អាចនាំឱ្យខូចដល់:

- សួត (Pneumonia)
- ឈាម (Bacteremia) និង
- ស្រោមខួរក្បាល (Meningitis)

ជម្ងឺរលាកសួត Pneumococcal អាចសម្លាប់មនុស្សម្នាក់ក្នុងចំណោម ២០ នាក់ដែលមានរោគ ។ រោគ Bacteremia អាចសម្លាប់មនុស្សម្នាក់ក្នុងចំណោម ៥ នាក់ ហើយរោគ Meningitis អាចសម្លាប់មនុស្ស៣នាក់ ក្នុងចំណោម ១០ នាក់ ។

អ្នកណាដែលមានបញ្ហាសុខភាពដូចបានរៀបរាប់ក្នុងផ្នែកទី៣ ភាគច្រើនប្រហែលអាចស្លាប់នឹងជម្ងឺនេះ ។

## 2 ថ្នាំចាក់បង្ការរោគ Pneumococcal polysaccharide (PPSV)

ការព្យាបាលការឆ្លងជម្ងឺ Pneumococcal ដោយប្រើថ្នាំ Penicillin និងថ្នាំផ្សេងៗទៀតធ្លាប់តែមានប្រសិទ្ធភាពគ្រាន់បើ ។ ប៉ុន្តែមានបណ្តាញជម្ងឺខ្លះៗអាចទប់ទល់នឹងថ្នាំបាន ។ ដូច្នេះធ្វើឱ្យការទប់ស្កាត់នឹងជម្ងឺផ្សេងៗដោយប្រើការចាក់ថ្នាំរឹត តែសំខាន់ទៅទៀត ។

ថ្នាំចាក់បង្ការ PPSV អាចការពារមេរោគ Pneumococcal បាន២៣បែប ដោយរួមទាំងជម្ងឺណាដែលនឹងអាចបង្ករឱ្យឈឺខ្លាំងផង ។

មនុស្សចាស់ណាដែលមានសុខភាពល្អ ហើយដែលបានចាក់ថ្នាំបង្ការ អាចការពារបាននឹងជម្ងឺរបៀបនេះភាគ ច្រើនក្នុងរយៈ២ឬ៣អាទិត្យក្រោយចាក់ថ្នាំរួច ។ មនុស្សចាស់ជរា — ក្មេងៗក្រោម២ឆ្នាំ នឹងមនុស្សណាដែលមានជម្ងឺរ៉ាំរ៉ៃមកហើយមិនសូវជាត្រូវជាមួយថ្នាំនេះល្អទេ ឬក៏អត់សោះតែម្តង ។

មានថ្នាំចាក់ Pneumococcal មួយទៀតឈ្មោះ Pneumococcal Conjugate Vaccine – PCV ដែលតែងតែណែនាំជាប្រចាំសំរាប់ឱ្យក្មេងក្រោមអាយុ៥ឆ្នាំប្រើ ។ PCV នឹងរៀបរាប់នៅក្នុងសេចក្តីរាយការណ៏ ផ្សេងមួយទៀត ។

## 3 តើអ្នកណាត្រូវទទួល PPSV?

- មនុស្សចាស់ទាំងអស់អាយុពី ៦៥ឆ្នាំឡើងទៅ ។
- មនុស្សពី២ទៅ៦៤ឆ្នាំ ដែលមានបញ្ហាសុខភាពយូរអង្វែងមកហើយដូចជា:
  - ជម្ងឺបេះដូង
  - ជម្ងឺសួត
  - ជម្ងឺក្នុងកោសិកា
  - ទឹកនោមផ្អែម
  - ញៀនគ្រឿងស្រវឹង
  - ជម្ងឺថ្លើម
  - មានធ្លាយទឹកនៅសរសៃជាប់ខួរក្បាលនឹងឆ្អឹងខ្នង ឬនៅកន្លែងបញ្ចូលសរីរាង្គ cochlear
- មនុស្សពី២ទៅ៦៤ឆ្នាំណាដែលមានជម្ងឺ ឬមានលក្ខណៈធ្វើឱ្យខ្លួនចេះតែខ្សោយទៅៗ ក្នុងការទប់ទល់នឹងការឆ្លងដូចជា:
  - ជម្ងឺ Hodgkin
  - ជម្ងឺដុះសាច់នៅសរសៃឈាមកោសិការ-ស ឬមហារីកឈាម
  - ខូចតំរងទឹកនោម
  - មានដុះសាច់នៅក្នុងខួរឆ្អឹងជាច្រើន
  - សញ្ញាមិនធម្មតានៅម៉ុំតំរងទឹកនោម
  - ជម្ងឺ HIV/AIDS
  - ខូច សរីរាង្គ spleen ឬគ្មាន spleen
  - ការវះកាត់ប្តូរសរីរាង្គ
- មនុស្សពី២ទៅ៦៤ឆ្នាំណាដែលប្រើថ្នាំឬមានការព្យាបាលដើម្បីធ្វើឱ្យខ្លួនចេះតែខ្សោយទៅៗ ក្នុងការទប់ទល់នឹងការឆ្លងដូចជា:
  - ប្រើថ្នាំ Steroids អស់រយៈពេលយូរ
  - ថ្នាំមហារីកខ្លះ
  - បញ្ចាំងភ្លើងបញ្ចូលថាមពល
- មនុស្សពី ១៩ ទៅ ៦៤ឆ្នាំ ណាដែល:
  - ជាអ្នកជក់បារី
  - មានរោគហឺត

PPSV ប្រហែលជាមិនសូវមានប្រសិទ្ធភាពដល់មនុស្សខ្លះ ពិសេសអ្នកដែលមិនសូវទប់ទល់នឹងការឆ្លងបាន ។

ប៉ុន្តែមនុស្សទាំងនេះគួរតែត្រូវចាក់ថ្នាំបង្ការព្រោះពួកគេនឹងមានការលំបាកវិតតែខ្លាំង បើគេមានជម្ងឺ Pneumococcal ។

ក្មេងដែលតែងតែមានជម្ងឺដំបៅត្រចៀក ជម្ងឺតឹងច្រមុះជានិច្ច ឬជម្ងឺនឹងបំពង់ដកដង្ហើមផ្នែកខាងលើ ប៉ុន្តែក៏នៅតែមានសុខភាពល្អដែរនោះ មិនចាំបាច់ត្រូវការ PPSV ទេព្រោះវានឹងគ្មានប្រសិទ្ធភាពចំពោះលក្ខណៈនោះឡើយ ។

## 4 តើត្រូវការថ្នាំ PPSV កំរិតប៉ុន្មានទៅ ហើយនៅពេលណា?

ធម្មតាត្រូវការតែមួយកំរិតទេ តែក្នុងលក្ខខ័ណ្ឌខ្លះអាចត្រូវការពីរកំរិត ។

- កំរិតទី២ត្រូវបានណែនាំសំរាប់មនុស្ស៦៥ឆ្នាំឡើងទៅ ដែលបានទទួលកំរិតទី១កាលពី-នៅក្រោមអាយុ៦៥ឆ្នាំហើយដែលបានទទួល៥ឆ្នាំឡើងទៅ ក្រោយពីកំរិតទី១ ។
- កំរិតទី២ត្រូវបានណែនាំសំរាប់មនុស្សអាយុ ២ឆ្នាំ រហូតដល់ ៦៤ ឆ្នាំ ដែលៈ
  - មានការខូចខាត ផាល Spleen ឬក៏គ្មាន ផាល
  - មានជម្ងឺដែលមានកោសិការាងដូចកណ្ដៀវ
  - បានឆ្លងរោគ HIV និង AIDS
  - មានមហារីក ជម្ងឺដុះសាច់នៅសរសៃឈាមកោសិការ-ស ឬមហារីកឈាម មានដុះសាច់នៅក្នុងខួរឆ្អឹងជាច្រើន
  - មានសញ្ញាមិនធម្មតានៅម្ដុំតំរងទឹកនោម
  - ការវះកាត់ប្ដូរសរីរាង្គ ឬប្ដូរខួរឆ្អឹង
  - ដែលកំពុងតែប្រើថ្នាំដើម្បីឱ្យភាពស៊ាំចុះថយ (ដូចជាការព្យាបាលបញ្ចាំងភ្លើងបញ្ចូលថាមពល និងចាក់ថ្នាំ Steroids អស់រយៈពេលយូរ)

ពេលត្រូវការទទួលកំរិតទី២ ត្រូវចាំ៥ឆ្នាំសិនក្រោយពេលទទួលកំរិតទី១ ។

## 5 អ្នកខ្លះមិនត្រូវទទួល PPSV ឬត្រូវរង់ចាំ

- អ្នកណាដែលមានប្រតិកម្មនឹងថ្នាំ PPSV ដល់ទៅស្លាប់រស់ មិនត្រូវទទួលកំរិតទី២ទេ ។
- អ្នកណាដែលមានប្រតិកម្មខ្លាំងនឹងផ្នែកមួយនៃថ្នាំ មិនត្រូវទទួលថ្នាំនោះទេ ។ សូមប្រាប់ទៅអ្នកថែទាំរបស់អ្នកបើសិនអ្នកមានប្រតិកម្មខ្លាំង ។
- អ្នកណាដែលឈឺចាប់ល្មម១ ឬខ្លាំងចំពេលដែលការចាក់ថ្នាំបានគ្រោងទុក ប្រហែលត្រូវសុំឱ្យរង់ចាំ រហូតស្រួលខ្លួនវិញទើបទទួលការចាក់ថ្នាំ ។ អ្នកណាឈឺតិចតួចអាចចាក់ថ្នាំបាន ។
- ទោះជាគ្មានភ័ស្ដុតាងថាថ្នាំ PPSV មានគ្រោះថ្នាក់ដល់ស្ត្រីមានគភ៌ឬកូនក្នុងផ្ទៃក្ដី ថ្នាំនេះមិនគួរចាក់ទេនៅពេលមានផ្ទៃពោះ ។ ស្ត្រីមានគភ៌ដែលមានជម្ងឺរ៉ាំរ៉ៃ គួរពិភាក្សាជាមួយអ្នកផ្ដល់សុខភាពសិនមុនទទួលចាក់ថ្នាំ ។ ស្ត្រីណាដែលមានលក្ខណៈមិនល្អស្រាប់ដឹងថានឹងមានគ្រោះថ្នាក់ចំពោះជម្ងឺ Pneumococcal ត្រូវចាក់ថ្នាំមុនពេលមានគភ៌ បើអាចធ្វើទៅបាន ។

## 6 តើថ្នាំ PPSV មានគ្រោះថ្នាក់អ្វីខ្លះ?

ប្រហែលមានមនុស្សចាក់ថ្នាំ PPSV ពាក់កណ្ដាលដែលអាចមានហេតុផលមិនល្អ តិចតួច ដូចជាមានឡើងពិណក្រហម ឬឈឺត្រង់កន្លែងចាក់ ។ ការក្ដៅខ្លួន ឈឺសាច់ដុំ ឬមានប្រតិកម្មវិតតែខ្លាំង គឺមានចំនួនតិចជាង១ភាគរយប៉ុណ្ណោះ ។

ថ្នាំចាក់ក៏ដូចថ្នាំដទៃដែរ អាចមានប្រតិកម្មខ្លាំងមួយបាន ។ ប៉ុន្តែគ្រោះថ្នាក់ក្នុងការចាក់ថ្នាំដែលនាំឱ្យឈឺចាប់ ឬស្លាប់ គឺមានតិចណាស់ ។

## 7 ចុះបើសិនមានប្រតិកម្មដ៏ខ្លាំងវិញនោះ?

### តើខ្ញុំត្រូវគិតសំគាល់រកអ្វី?

អ្នកត្រូវរកមើលលក្ខណៈមិនធម្មតាណាមួយ ដូចជាមានការប្ដូរកំដៅខ្លួនខ្លាំង ឬប្ដូរអាកប្បកិរិយា ។ សញ្ញានៃប្រតិកម្មខ្លាំងអាចមានដូចជាកាពិបាកដកដង្ហើម ស្អកក ក្អកស្ងួត ចេញពងលើស្បែក ឡើងស្លេក ចុះខ្សោយ បេះដូងដើរញាប់ ឬវិលមុខ ។

### តើខ្ញុំត្រូវធ្វើដូចម្ដេច?

- ទូរស័ព្ទទៅគ្រូពេទ្យ ឬ យកអ្នកនោះទៅជួបគ្រូពេទ្យជាបន្ទាន់ ។
- ជំរាបគ្រូពេទ្យថាមានរឿងអ្វី ថ្ងៃណាម៉ោងណា ហើយចាក់ថ្នាំម៉ោងប៉ុន្មាន ។
- សុំឱ្យអ្នកផ្ដល់សុខភាពរបស់អ្នករាយការណ៍ប្រតិកម្មដោយបំពេញក្រដាស Vaccine Adverse Event Reporting System (VAERS). ឬអ្នកអាចធ្វើសេចក្ដីរាយការណ៍ដោយចុចទៅ www.vaers.hhs.gov ឬទូរស័ព្ទទៅ 1-800-822-7967.

*VAERS ឥតមានតំបូន្មានឱ្យអ្នកទេ ។*

## 8 តើខ្ញុំអាចដឹងបន្ថែមតាមរបៀបណា?

- សួរអ្នកផ្ដល់សុខភាពរបស់អ្នក គេអាចឱ្យក្រដាសស្នាមស្ដីអំពីការចាក់ថ្នាំ ឬគេអាចផ្ដល់ពត៌មានអ្វីផ្សេងទៀត ។
- ទូរស័ព្ទទៅក្រសួងសុខភាពប្រចាំតំបន់អ្នក ឬ ប្រចាំខេត្រ ។
- ទាក់ទងការិយាល័យ Centers for Disease Control and Prevention (CDC) ដោយទូរស័ព្ទទៅ លេខៈ
  - 1-800-232-4636 (1-800-CDC.INFO)
  - ឬចុចទៅ www.cdc.gov/vaccines ។

DEPARTMENT OF HEALTH AND HUMAN SERVICES
CENTERS FOR DISEASE CONTROL AND PREVENTION

Vaccine Information Statement
PPSV (4/16/09) - Khmer (Cambodian) 42 U.S.C. § 300aa-26

Translation provided by the Minnesota Department of Health